ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាធារណបណ្ឌ
សំណុំរឿងព្រហ្មទណ្ឌស្រុបទោស
លេខ ១៧៣
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩
សាលដីកាស្រុបទោស
លេខ ៣០ "II"
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## គោលនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើពាក្យសុំស្រុបទោស ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] សុចិត្រ ជាមេធាវីតំណាង និងការពារក្ដីឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន, ឈ្មោះ [redacted] ឈឿន, ឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ក្នុងសំណុំរឿងលេខ ១៧៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់តុលាការកំពូល ដែលមាន ៖

-បុគ្គលប្ដឹងសុំ ៖ មេធាវី [redacted] សុចិត្រ ជាមេធាវីតំណាងឱ្យទណ្ឌិតចំនួន ០៤ នាក់ គឺ

១. ទណ្ឌិតឈ្មោះ [redacted] ឆេន ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ និងនេសាទត្រី ទីលំនៅ [redacted] ខេត្តកំពង់ឆ្នាំង (បច្ចុប្បន្នកំពុងឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែ "ម៤" ខេត្តពោធិ៍សាត់)។



Scanned with CamScanner

២. ទណ្ឌិតឈ្មោះ [redacted] ឈឿន ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ និងនេសាទត្រី ទីលំនៅមុនពេលចាប់ខ្លួន [redacted] ខេត្តកំពង់ឆ្នាំង (បច្ចុប្បន្នកំពុងឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែ "ម៤" ខេត្តពោធិ៍សាត់)។

៣. ទណ្ឌិតឈ្មោះ [redacted] ហុន ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាលប៉ុស្ដិ៍ស្រឡៅ ទីលំនៅមុនពេលចាប់ខ្លួន [redacted] ខេត្តកំពង់ធំ (បច្ចុប្បន្នកំពុងឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែ "ម៤" ខេត្តពោធិ៍សាត់)។

៤. ទណ្ឌិតឈ្មោះ [redacted] អ៊ី ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីលំនៅមុនពេលចាប់ខ្លួន [redacted] ខេត្តកំពង់ធំ (បច្ចុប្បន្នកំពុងឃុំខ្លួនក្នុងពន្ធនាគារខេត្តកំពង់ឆ្នាំង)។

- ទណ្ឌិតទាំង ០៤ នាក់នេះ មានលោកមេធាវី [redacted] សុចិត្រ ជាអ្នកការពារ។

**កម្មវត្ថុ ៖** ប្តឹងស្នើសុំអនុវត្តស្រូបទោសបញ្ចូលគ្នា រវាងទោសដាក់ពន្ធនាគារតាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពររបស់តុលាការកំពូលចំនួន ០២ និងសាលក្រមស្ថាពររបស់តុលាការសាលាដំបូងខេត្តកំពង់ឆ្នាំងចំនួន ០១ និងសុំកែតម្រូវឈ្មោះទណ្ឌិតចំនួន ០២ នាក់គឺ (១) កែតម្រូវពីឈ្មោះ [redacted] បាន ទៅជាឈ្មោះ [redacted] ហុន និង(២) ពីឈ្មោះ [redacted] ឆេម ទៅជាឈ្មោះ [redacted] ឆេន។

## មូលហេតុនៃបណ្ដឹង

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុចិត្រ ជាប្រធានការិយាល័យមេធាវី ប៊ី អ៊ឹម ស៊ី លីហ្គល & អេដវ៉ាយស័រ និងជាមេធាវីតំណាង និងការពារក្តីឱ្យលោក [redacted] ឆេន, លោក [redacted] ឈឿន, លោក [redacted] ហុន និងលោក [redacted] អ៊ី បានបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបាទគឺលោក [redacted] ឆេន, លោក [redacted] ឈឿន, លោក [redacted] ហុន និងលោក [redacted] អ៊ី ត្រូវបានតុលាការធ្វើការផ្តន្ទាទោសតាមអំណាចសាលដីកាស្ថាពរដូចខាងក្រោម ៖

១. ករណីលោក [redacted] ឆេន និងលោក [redacted] ឈឿន ៖

លោក [redacted] ឆេន និងលោក [redacted] ឈឿន ត្រូវបានតុលាការកំពូលផ្តន្ទាទោស និងកំពុងអនុវត្តទោសតាមអំណាចសាលដីកាស្ថាពរដូចខាងក្រោម ៖

ក. សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលសម្រេចផ្តន្ទាទោសអ្នកទាំងពីរដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០០ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២១ ខែមិថុនាឆ្នាំ២០០០ វេលាម៉ោង ៧ យប់ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។



Scanned with CamScanner

ខ. សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល សម្រេចផ្តន្ទាទោសអ្នកទាំងពីរដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ ពីបទ ភេរវកម្មជំរិតទារប្រាក់ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០០ បទល្មើសមានថែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០២ នៃច្បាប់ស្តីពីភេរវកម្ម និងមាត្រា ៣២, ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ករណីរបស់លោក [redacted] ឆេន និងលោក [redacted] ឈឿន ខាងលើនេះ កូនក្តីខ្ញុំស្នើសុំឱ្យតុលាការកំពូលធ្វើការ ស្រូបទោសដែលផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ ទៅក្នុងទោសដែលផ្តន្ទាដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ និងសុំអនុវត្តទោសពន្ធនាគាររយៈពេលតែ ២០ ឆ្នាំ សម្រាប់បទល្មើសទាំងពីរខាងលើនេះ គិតចាប់ពីថ្ងៃចាប់ខ្លួន។

២. ករណីលោក [redacted] ហុន និងលោក [redacted] អ៊ី ៖

លោក [redacted] ហុន និងលោក [redacted] អ៊ី ត្រូវបានតុលាការផ្តន្ទាទោស និងកំពុងអនុវត្តទោសតាមអំណាចសាលក្រម និងសាលដីកាស្ថាពរដូចខាងក្រោម៖

ក. សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង សម្រេចផ្តន្ទាទោសអ្នកទាំងពីរដាក់ពន្ធនាគារកំណត់ ០៥ ខែ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០០ តទៅពីបទ ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសំពោងសែន ឃុំសំពោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០ បទល្មើសមានថែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ. សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល សម្រេចផ្តន្ទាទោសលោក [redacted] ហុន ដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០០ និងលោក [redacted] អ៊ី ដាក់ពន្ធនាគារកំណត់ ០៩ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០០០ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០០ វេលាម៉ោង ២ យប់ បទល្មើសមានថែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

គ. សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល សម្រេចផ្តន្ទាទោសអ្នកទាំងពីរដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ ពីបទ ភេរវកម្មជំរិតទារប្រាក់ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង



Scanned with CamScanner

កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០២ នៃច្បាប់ស្តីពីភេរវកម្ម និងមាត្រា ៣២, ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ករណីរបស់លោក [redacted] ហុន និងលោក [redacted] អ៊ី ខាងលើនេះ កូនក្តីខ្ញុំស្នើសុំឱ្យតុលាការកំពូលធ្វើការស្រូបទោសដែលផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ ខែ ០៥ ឆ្នាំ (ករណី មុំ ហុន) និង ០៩ ឆ្នាំ ( ករណី [redacted] អ៊ី) ទៅក្នុងទោសដែលផ្តន្ទាដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ និងសុំអនុវត្តទោសដាក់ពន្ធនាគាររយៈពេលតែ ២០ ឆ្នាំ សម្រាប់បទល្មើសទាំងបីខាងលើនេះ គិតចាប់ពីថ្ងៃចាប់ខ្លួន។

៣. ករណីសុំកែតម្រូវឈ្មោះ [redacted] បាន ទៅជាឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] ឆែម ទៅឈ្មោះ [redacted] ឆេន នៅក្នុងសាលដីកាសម្រេចស្រូបទោស៖

នៅក្នុងសាលដីកាព្រហ្មទណ្ឌស្ពាលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល និងសាលដីកាព្រហ្មទណ្ឌស្ពាលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលសរសេរឈ្មោះលោក [redacted] ហុន ទៅជាឈ្មោះ [redacted] បាន និងឈ្មោះ [redacted] ឆេន ទៅជាឈ្មោះ [redacted] ឆែម គឺជាកំហុសបច្ចេកទេសក្នុងការសរសេរ ដោយសារថា យោងតាមឯកសារនានាដូចខាងក្រោមគឺឈ្មោះដែលត្រឹមត្រូវពិតប្រាកដគឺឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] ឆេន មិនមែនឈ្មោះ [redacted] បាន និងឈ្មោះ [redacted] ឆែម នោះទេ៖

ក. សំរង់សាលក្រមព្រហ្មទណ្ឌចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំងសរសេរថាឈ្មោះ [redacted] ហុន។

ខ. ដីកាឃុំខ្លួនលេខ ១០៦ ដ.ឃ.ខ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំងសរសេរថាឈ្មោះ [redacted] ហុន។

គ. សំរង់សាលដីកាព្រហ្មទណ្ឌលេខ ៤៦ (ជ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍សរសេរថាឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] ឆេន។

ឃ. សំរង់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ (ជ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍សរសេរថាឈ្មោះ [redacted] ហុន និង ឈ្មោះ [redacted] ឆេន។

ង. លិខិតលេខ ៩២/១៩ ព.គ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ស្តីពីសកម្មភាពរបស់ពិរុទ្ធជន/ទណ្ឌិតបញ្ជាក់ថាឈ្មោះ [redacted] ឆេន។

ក្នុងរយៈពេលនៃការអនុវត្តទោសនៅក្នុងពន្ធនាគារ កូនក្តីខ្ញុំបាទទាំងបួននាក់ខាងលើនេះបានអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងក្នុងបរិវេណពន្ធនាគារជាប្រចាំ ចូលរួមធ្វើពលកម្ម សំអាតអនាម័យក្នុងបន្ទប់បរិវេនពន្ធនាគារជាប្រចាំ ខិតខំរៀនសូត្របទវិន័យរបស់ពន្ធនាគារបានយ៉ាងល្អ ខិតខំរៀនសូត្រ



Scanned with CamScanner

ធម៌សម្រាប់អប់រំចិត្តឱ្យបានស្ងប់ស្ងាត់បានយ៉ាងល្អ មានទំនាក់ទំនងយ៉ាងល្អក្នុងការរស់នៅជាមួយជនជាប់ឃុំដទៃទៀតដូចជា ការនិយាយស្តីចេះគោរពគ្នា និងមានចរិកសុភាពរៀបសារ ដែលអាចធ្វើជាពលរដ្ឋល្អ និងចូលរួមរស់ក្នុងសង្គមឡើងវិញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង សម្រេចផ្តន្ទាទោសឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដាក់ពន្ធនាគារកំណត់ ០៥ ខែ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០០ តទៅ ពីបទ ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសំរោងសែន ឃុំសំរោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល បានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៦ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ធេន, ឈ្មោះ [redacted] ឈឿន, ឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដាក់ពន្ធនាគារកំណត់ចំនួន ២០ឆ្នាំ ពីបទ ភេរវកម្មជំរិតទារប្រាក់ សម្លាប់មនុស្ស និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០២ នៃច្បាប់ស្តីពីភេរវកម្ម និងមាត្រា ៣២, ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល បានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ធេន, ឈ្មោះ [redacted] ឈឿន និងឈ្មោះ [redacted] ហុន ដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០០ និងឈ្មោះ [redacted] អ៊ី ដាក់ពន្ធនាគារកំណត់ ០៩ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០០ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០ វេលាម៉ោង ២ យប់ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញ ពាក្យសុំស្រូបទោស ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] សុចិត្រ ជាមេធាវីតំណាង និងការពារក្តីឱ្យទណ្ឌិតឈ្មោះ [redacted] ធេន, ឈ្មោះ [redacted] ឈឿន, ឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍



Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា ទណ្ឌិតទាំងបួននាក់ដែលមានឈ្មោះ[redacted]ឆេន,[redacted]ឈឿន,[redacted]ហុន,[redacted]អ៊ី ដែលតុលាការកំពូល សម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ដែលមាន (១).ទណ្ឌិតឈ្មោះ[redacted]ឆេន និងឈ្មោះ[redacted]ឈឿន ត្រូវបានផ្ដន្ទាទោស ០៥ (ប្រាំ)ឆ្នាំពីបទៈ ប្លន់។សាលដីកាព្រហ្មទណ្ឌលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ ផ្ដន្ទាទោស ២០ (ម្ភៃ) ឆ្នាំ ពីបទៈ កេរវែកម្មជំរិតទារប្រាក់ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់។ សុំអនុវត្តទោសតែ ២០(ម្ភៃ)ឆ្នាំ។ និង(២).ទណ្ឌិតឈ្មោះ[redacted]ហុន និងឈ្មោះ[redacted]អ៊ី តាមសាលក្រមព្រហ្មទណ្ឌលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ បានផ្ដន្ទាទោសក្នុងម្នាក់ៗ ០៥(ប្រាំ)ឆ្នាំ ពីបទៈ ប្រើប្រាស់អាវុធខុសច្បាប់។ និងសាលក្រមព្រហ្មទណ្ឌលេខ ៤៤ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១១ ផ្ដន្ទាទោសទណ្ឌិតឈ្មោះ[redacted]ហុន ដាក់ពន្ធនាគារ ០៥(ប្រាំ)ឆ្នាំ ពីបទៈ ប្លន់ និងទណ្ឌិតឈ្មោះ[redacted]អ៊ី ដាក់ពន្ធនាគារ ០៩(ប្រាំបួន)ឆ្នាំ ពីបទៈ ប្លន់។ ដូចនេះសូមក្រុមប្រឹក្សាជំនុំជម្រះ គួរអនុវត្តតាមមាត្រា ១៣៨ ចំណុច១ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី[redacted]សុចិត្រ បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនទាំង០៤នាក់ គឺគាត់ទទួលទោសតាមអំណាចសាលដីកាតុលាការកំពូលគឺមានចំនួន ០២៖ ទី០១គឺ សាលដីកាលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ ពាក់ព័ន្ធនឹងបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលក្នុងនោះផ្ដន្ទាទោសអ្នកទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ដូចគ្នានិងទី២ សាលដីកាស្ថាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល ផ្ដន្ទាទោសអ្នកទាំង០៤នាក់ ដាក់ពន្ធនាគារកំណត់រយៈពេល២០(ម្ភៃ)ឆ្នាំ ពីបទ កេរវែកម្មជំរិតទារប្រាក់ ប្រព្រឹត្តនៅភូមិជើងគ្រោះ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ ដោយឡែកករណីពិសេស គឺកូនក្ដីខ្លួនឈ្មោះ[redacted]ហុន និងឈ្មោះ[redacted]អ៊ី បន្ថែមពីលើសាលដីកាស្ថាពរទាំង០២ របស់តុលាការកំពូល គឺគាត់មានទោសមួយទៀត គឺប្រើប្រាស់អាវុធខុសច្បាប់ ដែលត្រូវបានតុលាការខេត្តកំពង់ឆ្នាំងធ្វើការផ្ដន្ទាទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថានពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ប្រព្រឹត្តនៅភូមិ សំរោងសែន ឃុំសំរោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មូលហេតុដែលកូនក្ដីខ្លួន ស្នើសុំឱ្យតុលាការកំពូលស្រូបទោសគឺ ឈ្មោះ[redacted]ឆេន និង[redacted]ឈឿន សុំស្រូបទោស០៥(ប្រាំ)ឆ្នាំ ចូលទៅក្នុងទោស ២០(ម្ភៃ)ឆ្នាំ ហើយសុំអនុវត្តទោស ២០(ម្ភៃ)ឆ្នាំ ចំណែកឈ្មោះ[redacted]ហុន និង[redacted]អ៊ី សុំស្រូបទោស ០៥(ប្រាំ)ឆ្នាំ និងទោស ០៥(ប្រាំ)ខែ ចូលទៅក្នុងទោស ២០(ម្ភៃ)ឆ្នាំ ហើយអនុវត្តទោសតែ ២០(ម្ភៃ)ឆ្នាំ ។ យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌដែលចែងពាក់ព័ន្ធទៅនឹងការអនុវត្តទោសត្រួតគ្នា ក្នុងព្រំដែន អតិប្បរមា ដែលខ្ពស់ជាងគេ ដែលនេះគឺជាសិទ្ធិអំណាចរបស់តុលាការក្នុងសម្រេច។ ដូច្នេះក្នុងនាមខ្លួនជាមេធាវី តំណាងឱ្យ ទណ្ឌិតទាំង០៤រូប ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចស្រូបទោសរបស់ទណ្ឌិតទាំង ០៤រូបនេះ សុំអនុវត្តត្រឹមតែ ២០ (ម្ភៃ)ឆ្នាំ។



Scanned with CamScanner

-ទណ្ឌិតឈ្មោះ [redacted] ឆេន បានឆ្លើយថា ខ្លួនស្នើសុំឱ្យឯកឧត្តមប្រធានតុលាការ មេត្តាជួយស្រូបទោសឱ្យខ្លួន ដើម្បីឱ្យខ្លួនឆាប់បានចេញវិលទៅរកគ្រួសារវិញ។

-ទណ្ឌិតឈ្មោះ [redacted] ឈឿន បានឆ្លើយថា ខ្លួនសំណូមពរដាក់ឯកឧត្តមប្រធានតុលាការ មេត្តាជួយស្រូបទោសឱ្យរូបខ្លួន ដើម្បីឱ្យខ្លួនឆាប់បានចេញទៅរស់នៅក្នុងសង្គម និងធ្វើប្រជាពលរដ្ឋល្អ និងបានជួបជុំគ្រួសារវិញផង។

-ទណ្ឌិតឈ្មោះ [redacted] ហុន បានឆ្លើយថាសុំឱ្យឯកឧត្តមប្រធានតុលាការមេត្តាជួយស្រូបទោសឱ្យខ្លួនដើម្បីឆាប់បានចេញទៅជួបជុំគ្រួសារ និងធ្វើជាពលរដ្ឋល្អវិញ។

-ទណ្ឌិតឈ្មោះ [redacted] អ៊ី បានឆ្លើយថា ខ្លួនសំណាមពរ សុំឱ្យឯកឧត្តមមេត្តា ជួយស្រូបទោសនូវត្រឹម ២០ឆ្នាំ ដើម្បីឆាប់បានវិលត្រលប់ទៅផ្ទះវិញ បំរើឪពុកម្តាយចាស់ជរា។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិតនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារក្តី
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់លោក [redacted] សុចិត្រ ជាមេធាវីតំណាងឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន, ឈ្មោះ [redacted] ឈឿន, ឈ្មោះ [redacted] ហុន, និងឈ្មោះ [redacted] អ៊ី ប្តឹងសុំស្រូប ទោសបញ្ចូលគ្នា និងសុំកែតម្រូវឈ្មោះទណ្ឌិតចំនួន ២ នាក់ គឺកែពីឈ្មោះ [redacted] បាន ទៅជា [redacted] ហុន និងកែពីឈ្មោះ [redacted] ឆេម ទៅជា [redacted] ឆេន ធ្វើឡើងស្របតាមបទប្បញ្ញត្តិមាត្រា ៥០១ និងមាត្រា ៦០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកពិនិត្យ ពិចារណា វិនិច្ឆ័យ សម្រេចសេចក្តីជាសមត្ថកិច្ចបាន។

២-យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៩ របស់មេធាវីតំណាងឱ្យទណ្ឌិតទាំង ៤ នាក់ ក៏ដូចជាអំណះអំណាងការពាររបស់មេធាវីនាពេលពិភាក្សាដេញដោលដែរ លោកមេធាវីបានសុំឱ្យតុលាការកំពូលធ្វើការកែតម្រូវឈ្មោះទណ្ឌិតចំនួន ២ នាក់ គឺកែពីឈ្មោះ មុំ បាន ទៅជាឈ្មោះ [redacted] ហុន និងកែពីឈ្មោះ [redacted] ឆេម ទៅជាឈ្មោះ [redacted] ឆេន ដោយបានលើកឡើងថា សាលដីកាព្រហ្មទណ្ឌស្ពាពលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ និងលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលបានសរសេរខុសឈ្មោះ (នាមខ្លួន) របស់ទណ្ឌិតពីរនាក់ គឺឈ្មោះ [redacted] ហុន ទៅជាឈ្មោះ [redacted] បាន និងឈ្មោះ [redacted] ឆេន ទៅឈ្មោះ [redacted] ឆេម ។ ក្នុងករណីនេះ ពិនិត្យទៅលើកិច្ចរបស់តុលាការថ្នាក់ក្រោម ក៏ដូចជាសម្រង់សាលក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្ត



Scanned with CamScanner

កំពង់ឆ្នាំងដែរ បានសរសេរឈ្មោះទណ្ឌិតទាំង ២ នាក់ គឺឈ្មោះ [redacted] ហុន និង [redacted] ធេន ។ ឯក្នុងសម្រង់សាលដីកាព្រហ្មទណ្ឌលេខ ៤៦ (ជ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងសម្រង់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ (ជ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ ក៏បានសរសេរឈ្មោះរបស់ទណ្ឌិត គឺឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] ធេន ហើយសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទាំងពីរនេះត្រូវបានទណ្ឌិតប្ដឹងសាទុក្ខ។ ប៉ុន្តែក្នុងនីតិវិធីបណ្ដឹងសាទុក្ខនិងការតាក់តែងសាលដីកាព្រហ្មទណ្ឌលេខ ៤៣ និងលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ ដូចបង្ហាញខាងលើនេះ បានសរសេរឈ្មោះទណ្ឌិតទាំង ២ នាក់នេះ ទៅជាឈ្មោះ [redacted] បាន និងឈ្មោះ [redacted] ធេម ទៅវិញ ដែលជាសំណេរខុសនាមខ្លួនទណ្ឌិត ២ នាក់ ។ ការនេះចាត់ទុកថា ជាការភ័ន្តច្រឡំខាងសម្ភារៈ សុទ្ធសាធ ដោយមិនប៉ះពាល់ដល់ខ្លឹមសារជាសារជាតុនៃរឿងក្ដីនេះទេ។ យោងតាមបទប្បញ្ញត្តិមាត្រា ៦០៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលគប្បីធ្វើកំណែតម្រូវកំហុសឆ្គងផ្នែកសម្ភារៈ គឺនាមខ្លួន របស់ទណ្ឌិតទាំង ២ នាក់នេះឱ្យបានត្រឹមត្រូវ គឺឈ្មោះ [redacted] ហុន និង [redacted] ធេន ។

៣-យល់ឃើញថា មេធាវីការពារឱ្យទណ្ឌិតបានអះអាងក្នុងពាក្យបណ្ដឹងសុំស្រូបទោសបញ្ចូលគ្នា ក៏ដូចជាក្នុងកិច្ចពិភាក្សាដេញដោលដែរថា ៖

-សាលក្រមព្រហ្មទណ្ឌស្ពាពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង បានប្រកាសទោសលើទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ខែ ក្នុងម្នាក់ៗ ពីបទប្រើប្រាស់អាវុធខុសច្បាប់ តាមមាត្រា ៥៤ និងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-សាលដីកាព្រហ្មទណ្ឌស្ពាពរលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលដែលបាន សម្រេចតម្កល់សាលដីកាលេខ ៤៧ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានប្រកាសទោសលើទណ្ឌិត ៤ នាក់គឺឈ្មោះ [redacted] ហុន , [redacted] អ៊ី , [redacted] ធេន និងឈ្មោះ [redacted] ឈឿន ដាក់ពន្ធនាគារ ក្នុងម្នាក់ៗ កំណត់ ៥ (ប្រាំ) ឆ្នាំ ពីបទប្លន់ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ និង

-សាលដីកាព្រហ្មទណ្ឌស្ពាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៦ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេច និងប្រកាសទោសលើទណ្ឌិតទាំង ៤ នាក់ដដែលនេះ គឺឈ្មោះ [redacted] ហុន , [redacted] អ៊ី , [redacted] ធេន និង [redacted] ឈឿន ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ២០ (ម្ភៃ) ឆ្នាំ ពីបទភេរវកម្មជំរិតទាប្រាក់ សម្លាប់មនុស្សគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ តាមបទប្បញ្ញត្តិមាត្រា ២ នៃច្បាប់ស្ដីពីភេរវកម្ម ឆ្នាំ១៩៩២ និងមាត្រា ៣១ , មាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ហេតុនេះ ខ្លួនស្នើសុំឱ្យតុលាការសម្រេចស្រូបទោសបញ្ចូលគ្នា គឺទោសដាក់ពន្ធនាគារ ៥ ខែ និង ៥ ឆ្នាំ ដោយស្រូបទាំងស្រុងទៅក្នុងទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ពាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល ដែលបានសម្រេចតម្កល់សាលដីកា

Scanned with CamScanner

ព្រហ្មទណ្ឌលេខ ៤៦ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានប្រកាសទោសលើទណ្ឌិតទាំង ៤ នាក់ និងសុំឱ្យទណ្ឌិតទាំង ៤ នាក់ អនុវត្តទោសដាក់ពន្ធនាគារត្រឹម ២០ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួននោះ តុលាការកំពូលពិនិត្យឃើញថា៖

សាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារតែទៅលើទណ្ឌិតចំនួន ២ នាក់ទេ គឺទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដោយកំណត់រយៈពេល ៥ (ប្រាំ) ខែ ក្នុងម្នាក់ៗ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួន *ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០*។ សាលក្រមនេះបានចូលជាស្ថាពរ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ មកម្ល៉េះ ។ ដូច្នេះ ទោសដែលទណ្ឌិតទាំង ២ នាក់នេះ គឺឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី បានអនុវត្តទោសដាក់ពន្ធនាគារកំណត់ ៥ ខែ តាមអំណាច សាលក្រមនេះរួចហើយ ជាហេតុមិនអាចយកមកស្រូបបញ្ចូលជាមួយនឹងទោសតាមអំណាចសាលដីកាបស់តុលាការកំពូលចំនួន ២ បានទៀតទេ ពីព្រោះវាខុសនឹងគោលបំណងនៃការស្រូបទោសបញ្ចូលគ្នាគឺ *"ដើម្បី ដោះស្រាយការលំបាកទាក់ទងនឹងការអនុវត្តទោស"* ដូចមានបញ្ញត្តិក្នុងមាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-យល់ឃើញថា ករណីបណ្តឹងសុំនេះ មានតែសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៤ និងលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលប៉ុណ្ណោះ ដែលអាចជាកម្មវត្ថុនៃការស្រូបទោសបញ្ចូលគ្នាបាន ដែលតុលាការកំពូលគប្បីស្រូបទោសទាំងស្រុងនូវទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល ទៅក្នុងទោសជាប់ពន្ធនាគារ កំណត់ ២០ ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ ដោយផ្អែក តាមបទប្បញ្ញត្តិមាត្រា ១៣៦ និងមាត្រា ១៣៨ គ្រង់កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមាត្រា ៥០០ និងមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-យល់ឃើញថា ទណ្ឌិត ២ នាក់ គឺឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី បានអនុវត្តទោសដាក់ពន្ធនាគារកំណត់ ៥ ខែ គិតពីថ្ងៃចាប់ឃុំខ្លួន ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។ ដូច្នេះទោសនេះទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី បានអនុវត្តចប់នៅត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០០ ដែលជាហេតុតុលាការកំពូលយកធ្វើជាកាលបរិច្ឆេទឱ្យទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី *អនុវត្តទោសរួមចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០០* មក ក្រោយពីតុលាការកំពូលប្រកាស តាមអំណាចសាលដីកានេះ។

៦-យល់ឃើញថា ទណ្ឌិតឈ្មោះ [redacted] ធេន និងឈ្មោះ [redacted] ឈឿន ជាប់ទោសតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល ដែលបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ "ជ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ ឆ្នាំពីបទប្លន់ ដោយ*គិតចាប់ពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០* ។ ដូច្នេះ



Scanned with CamScanner

តុលាការកំពូលកំណត់យកកាលបរិច្ឆេទនេះជាចំណុចចាប់ផ្តើមគិតឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន និងឈ្មោះ [redacted] ឈឿន *អនុវត្តទោសរួម* ក្រោយពីតុលាការកំពូលប្រកាសតាមអំណាចសាលដីកានេះ។

៧-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលប្តឹងសុំឱ្យតុលាការកំពូលពិចារណាទៅតាមទិដ្ឋភាពច្បាប់និងផលប្រយោជន៍សង្គម។ ចំណុចនេះ តុលាការកំពូលបានលើកមកពិនិត្យ ពិចារណា វិនិច្ឆ័យ ដូចមានក្នុងសំអាងហេតុខាងលើនេះរួចអស់ហើយ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ក. ទទួលពាក្យបណ្តឹងចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុចិត្រ ជាមេធាវីតំណាងឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន , [redacted] ឈឿន , [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដែលបានប្តឹងសុំមួយផ្នែកនៃពាក្យប្តឹងសុំស្រូបទោសបញ្ចូលគ្នា និងផ្នែកបណ្តឹងសុំកែតម្រូវឈ្មោះទណ្ឌិតចំនួន ២ នាក់ ដោយកែពីឈ្មោះ [redacted] បាន ទៅជាឈ្មោះ [redacted] ហុន និងកែពីឈ្មោះ [redacted] ឆេម ទៅឈ្មោះ [redacted] ឆេន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

ខ. បដិសេធផ្នែកពាក្យបណ្តឹងចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុចិត្រ ជាមេធាវីតំណាងឱ្យទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី ដែលបានប្តឹងសុំឱ្យតុលាការកំពូលស្រូបបញ្ចូលគ្នានូវទោស ដាក់ពន្ធនាគារកំណត់ ៥ ខែ តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ពាលលេខ ១៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមូលហេតុខុសនឹងគតិច្បាប់ ។

២- កែតម្រូវឈ្មោះទណ្ឌិត ២ នាក់ ក្នុងសាលដីកាព្រហ្មទណ្ឌស្ពាលលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ និងសាលដីកាព្រហ្មទណ្ឌស្ពាលលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល គឺ កែពីឈ្មោះ [redacted] បាន ទៅជាឈ្មោះ [redacted] ហុន និងកែពីឈ្មោះ [redacted] ឆេម ទៅឈ្មោះ [redacted] ឆេន ។

៣- ស្រូបបញ្ចូលទោសដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ពាលលេខ ៤៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូលទាំងស្រុងចូលទៅក្នុងទោសដាក់ពន្ធនាគារកំណត់ ២០ (ម្ភៃ) ឆ្នាំក្នុងម្នាក់ៗ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល ឱ្យដល់ទណ្ឌិតឈ្មោះ [redacted] ឆេន , [redacted] ឈឿន , [redacted] ហុន និងឈ្មោះ [redacted] អ៊ី ។

តុលាការកំពូលប្រកាសទោសរួមឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន , [redacted] ឈឿន , [redacted] ហុន , និងឈ្មោះ [redacted] អ៊ី *អនុវត្តកំណត់ ២០ (ម្ភៃ) ឆ្នាំ ចំពោះទណ្ឌិតម្នាក់ៗ* ដោយ ៖

ក-ឱ្យទណ្ឌិតឈ្មោះ [redacted] ហុន និងឈ្មោះ [redacted] អ៊ី អនុវត្តទោសរួមកំណត់ ២០ (ម្ភៃ) ឆ្នាំ ដូចខាងលើនេះ (ទោសក្រោយពីស្រូបបញ្ចូលគ្នា) *គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០០* មក ។

ខ-ឱ្យទណ្ឌិតឈ្មោះ [redacted] ឆេន និងឈ្មោះ [redacted] ឈឿន អនុវត្តទោសរួមកំណត់ ២០ (ម្ភៃ) ឆ្នាំ ដូចខាងលើនេះ (ទោសក្រោយពីស្រូបបញ្ចូលគ្នា) *គិតចាប់ពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ មក។*

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលដីកាជាសាធារណៈនៅថ្ងៃសុក្រ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ៕

Scanned with CamScanner